# 5 សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារ
## ទំនប់ទឹកនៅចំការ

ប្រសិនបើលោកអ្នកចង់សង់ ឬពង្រីកទំនប់ទឹកនៅក្នុងបរិវេណដីធ្លីរបស់លោកអ្នក លោក អ្នកត្រូវដាក់ពាក្យសុំការអភិវឌ្ឍន៍ (DA) មួយទៅសាលាក្រុងរបស់លោកអ្នក។ សូមទាក់ទងជាមួយបុគ្គលិកផែនការនៅសាលាក្រុងរបស់លោកអ្នកដើម្បីសុំឱវាទ។

លោកអ្នកប្រហែលជាត្រូវការអាជ្ញាបណ្ណមួយផងដែរពីក្រសួងធនធានទឹក និងថាមពល (Department of Water and Energy) ដើម្បីសាងសង់ទំនប់ទឹករបស់លោកអ្នក។ ទំនប់ទឹកតូចៗដែលមិនសង់នៅតាមជ្ញរមាត់ព្រែក មិនចាំបាច់ត្រូវការអាជ្ញាបណ្ណទេ ប្រសិនបើទប់ទឹកនោះតិចជាង១០ភាគរយនៃទឹកដែលហូរចេញពីចំការរបស់លោកអ្នក។ ទោះជាយ៉ាងណាក្តី ប្រសិនបើលោកអ្នកមានទំនប់ទឹកឯទៀតរួចហើយ ឬលោកអ្នកមានបំណងចង់សង់ទំនប់ទឹកមួយនៅតាមមាត់ព្រែក លោកអ្នកនឹងត្រូវការអាជ្ញាបណ្ណមុននឹងសង់ទំនប់ទឹកនោះ។ ដើម្បីទទួលយកព័ត៌មានបន្ថែមទៀត សូមទាក់ទងជាមួយបុគ្គលិកចេញអាជ្ញាបណ្ណទឹក តាមទូរស័ព្ទលេខ 02 9895 7194 ដែលគេនឹងជំរាបលោកអ្នកឲ្យបានដឹងថាតើលោកអ្នកត្រូវការអាជ្ញាបណ្ណឬទេ។ លោកអ្នកអាចបានព័ត៌មានច្រើនថែមទៀតអំពីការចេញអាជ្ញាបណ្ណសំរាប់ទំនប់ទឹកនៅចំការ នៅតាមវ៉ិបសាយរបស់ក្រសួងធនធានទឹក និងថាមពលៈ

http://www.dnr.nsw.gov.au/water/dams.shtml



NSW DPI, Virginia Brunton



NSW DPI, Virginia Brunton

ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល បានផលិតនូវព័ត៌មានជាច្រើនដើម្បីជួយលោកអ្នកក្នុងការសង់ទំនប់ទឹករបស់លោកអ្នក។ លោកអ្នកអាចទាក់ទងជាមួយក្រសួងតាមទូរស័ព្ទលេខ 02 4588 2107 ឬអាចរកឃើញព័ត៌មាននៅតាមវ៉ិបសាយៈ
http://www.dpi.nsw.gov.au/agriculture/resources/water/storage

បញ្ហាទាំងឡាយដែលលោកអ្នកនឹងត្រូវគិតពិចារណានៅពេលសង់ទំនប់ទឹកគឺៈ

- ថាតើលោកអ្នកត្រូវដាក់ពាក្យសុំការអភិវឌ្ឍន៍ ឬអាជ្ញាបណ្ណសាងសង់ឬទេ
- ចំនួនទឹកដែលទំនប់ទឹកនេះអាចផ្ទុកទឹក
- ថាតើនរណានឹងត្រូវសង់ទំនប់ទឹក
- ទីកន្លែងដែលលោកអ្នកនឹងសង់ទំនប់ទឹក
- របៀបដែលលោកអ្នកនឹងមើលថែទំនប់ទឹក
- ថាតើទំនប់ទឹកនោះនឹងបណ្តាលឲ្យកើតមានការច្រោះដីឬទេ
- របៀបដែលទំនប់ទឹកនឹងមានផលប៉ះពាល់ដល់រុក្ខជាតិ និងសត្វទាំងឡាយនៅក្នុងតំបន់របស់លោកអ្នក
- របៀបដែលទំនប់ទឹកនឹងមានផលប៉ះពាល់ដល់វិធីដែលទឹកហូរឡើង និងហូរចុះពីបរិវេណដីធ្លីរបស់លោកអ្នក
- តើវត្ថុធាតុ ឬសម្ភារៈអ្វីខ្លះដែលនឹងត្រូវបានយកប្រើប្រាស់សំរាប់ការសង់ទំនប់ទឹក (ប្រសិនបើលោកអ្នកប្រើស៊ីម៉ង់ ឬគ្រឿងចាក់បំពេញយកមកពីប្រទេសក្រៅ លោកអ្នកនឹងត្រូវការសេចក្តីបញ្ជាក់អំពីការរួចផុតពីមេរោគ)។

### ការទាក់ទងៈ

ក្រសួងធនធានទឹក និងថាមពលៈ 02 9895 7194

ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែលៈ 02 4588 2107

**សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារនេះ** គឺជាផ្នែកនៃលំដាប់ព័ត៌មានគ្រោងឡើងដើម្បីជួយដល់អ្នកដំណាំដែលមកពីសាវតាមិននិយាយភាសាអង់គ្លេស។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយសាលាក្រុងក្នុងតំបន់របស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទ TIS លេខ 131 450។

គំរោងការនេះបានទទួលការផ្គត់ផ្គង់ពីរដ្ឋាភិបាលរដ្ឋញូវសៅវែល តាមរយៈមូលនិធិបរិដ្ឋានរបស់ខ្លួន (Environmental Trust)។

ព័ត៌មានដែលចុះនៅក្នុងការចុះផ្សាយនេះសំអាងទៅលើចំណេះដឹង និងការដឹងយល់នៅចំពេលកំពុងសរសេរ (ខែវិច្ឆិកា ឆ្នាំ២០០៧)។ ទោះជាយ៉ាងណាក្តី ដោយព្រោះតែការចំរើនលើចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកប្រាប់ពីសេចក្តីត្រូវការដើម្បីឲ្យបានប្រាកដថាព័ត៌មានដែលគេពឹងផ្អែកនោះគឺទាន់ពេលថ្មីៗ ហើយត្រូវឆែកមើលព័ត៌មានបច្ចុប្បន្នជាមួយភ្នាក់ងារសមស្របនៃក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល ឬជាមួយអ្នកប្រឹក្សាឯករាជ្យនៃអ្នកប្រើប្រាស់ព័ត៌មាននេះ។

NSW DEPARTMENT OF PRIMARY INDUSTRIES

NSW Environmental TRUST